ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល
១១១

សំណុំរឿងរដ្ឋប្បវេណី

លេខ : ៤៥៩

ចុះថ្ងៃទី០៧ខែធ្នូឆ្នាំ២០០០

សាលដីកា

លេខ : ៧០

ចុះថ្ងៃទី១០ខែឧសភាឆ្នាំ២០០១

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០១ ដោយមានសមាសភាពដូចតទៅ :-

១- ឯកឧត្តម ឌិត មុន្នី ជាប្រធាន

២- លោក ប៉ែន ស៊ិន ជាចៅក្រម

៣- លោក ជីវ កេង ជាចៅក្រម របាយការណ៍

៤- លោក យស់ សុខឡឹន ជាចៅក្រម

៥- លោក គង់ ភីរុន ជាចៅក្រម

ក្រឡាបញ្ជី

លោក គី សុផុន

តំណាងមហាអយ្យការ

លោក ប៉ែន សាវឿន ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ ៦៤ "ឌ" ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០០ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៨២៥ ចុះថ្ងៃទី២០ ខែ ធ្នូ ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខលោក មាស សេង អាយុ ៥២ ឆ្នាំ ជាតិ ខ្មែរ មុខរបរ ជួលជុលម៉ូតូ ទីលំនៅផ្ទះលេខ ៤៧០ ផ្លូវ ព្រះមុនីវង្ស សង្កាត់ ទន្លេបាសាក់ ខណ្ឌ ចំការមន ក្រុង ភ្នំពេញ . ឪពុកឈ្មោះ មាស ស៊ួង "ស" ម្តាយឈ្មោះ ឌួង ធួន "ស" ។

លោក ឡុង នរិន្ទ ជាមេធាវី

និង ចុងចម្លើយបណ្តឹងសាទុក្ខលោក គី ជិនណាន អាយុ ៤៨ ឆ្នាំ ជាតិ ខ្មែរ មុខរបរ ពាណិជ្ជករ ទីលំនៅ ផ្ទះលេខ ៤៧០ ផ្លូវ ព្រះមុនីវង្ស សង្កាត់ ទន្លេបាសាក់ ខណ្ឌ ចំការមន ក្រុងភ្នំពេញ ។ ផ្ទេរសិទ្ធិអោយលោក ជា ឃាមម៉ី

លោក ម៉ែម វុន ជាមេធាវី .

<u>កម្មវត្ថុបណ្តឹង</u> : ប្តឹងទាមទារអោយរុះរើសំណង់ចេញពីដីឡូតិ៍ លេខ ៤៧០ និង ទាមទារប្រាក់ឈ្នួល .

-- ---

បានឃើញបណ្តឹងសាទុក្ខលេខ ៣៩៣ ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០០ របស់លោក មាស សេង ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៦៤ "ឃ" ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ៤៥៩ ចុះថ្ងៃទី ០៧ ខែ ធ្នូឆ្នាំ ២០០០ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹង ចុះថ្ងៃទី ២៩.០៣.១៩៩៩ របស់ដើមចោទលោកជា ស្រ៊ុយ បញ្ជាក់ថា ខ្លួនបានជួលដីឡូត៍លេខ ៤៧០ ក្រុមទី ៥៦ សង្កាត់ទន្លេបាសាក់ ខណ្ឌ ចំការមន ក្រុងភ្នំពេញ អោយឈ្មោះ ភ្លី ញ៉ឹង នៅឆ្នាំ ១៩៩៥ ដោយបានធ្វើកិច្ចសន្យាត្រឹមត្រូវ ហើយក៏បានជួលដីឡូត៍នេះអោយឈ្មោះ មាស សេង នៅឆ្នាំ ១៩៩៦ តែអ្នកទាំងនោះពុំបានគោរពតាមកិច្ចសន្យា និង អ្វីដែលគេសរសេរនោះទេ ។ ហេតុនេះខ្លួនសូមប្តឹងពីឈ្មោះ ភ្លី ញ៉ឹង អោយរុះរើសំណង់អាជីវកម្មតូច ចេញពីដីឡូត៍ខាងលើ និង ទាមទារប្រាក់ថ្លៃឈ្នួល ចំនួន ៣៦០០ដុល្លា និង ប្តឹងពីឈ្មោះ មាស សេង អោយរុះរើសំណង់អាជីវកម្មជួលជុសរថយន្តចេញពីដីឡូត៍ខាងលើដែរនឹងទាមទារប្រាក់ថ្លៃឈ្នួល ចំនួន ៤៣០០ដុល្លាអាមេរិក ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ៩៤ "ក" ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ ១៩៩៩ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :-

១- ទទួលពាក្យបណ្តឹងរបស់ដើមចោទឈ្មោះ ជា ស្រ៊ុយ ចុះថ្ងៃទី ២៩ ខែ មិនា ឆ្នាំ ១៩៩៩ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- ទទួលស្គាល់ពាក្យសុំថណាយក្តីរបស់មេធាវី ពុធ ធារី ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ១៩៩៩ ដើម្បីការពារ និង ជាតំណាងអោយចុងចម្លើយ ឈ្មោះ មាស សេង ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

៣- រំលាយកិច្ចសន្យា ចុះថ្ងៃទី០១.១០.៩៥ រវាងឈ្មោះ ជា ស្រ៊ុយ និង ឈ្មោះ ភ្លី ញ៉ឹង ចោលជាអាសារបង់ តាមមាត្រា ១០៧ នៃក្រិត្យច្បាប់លេខ ៣៨ ចុះថ្ងៃទី ២៨.១០.១៩៨៨ ចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

៤- បង្គាប់អោយឈ្មោះ ភ្លី ញ៉ឹង ភេទស្រី អាយុ ៥៨ ឆ្នាំ និង ឈ្មោះ មាស សេង ភេទប្រុស អាយុ ៥២ ឆ្នាំ ដែលមានមេធាវីឈ្មោះ ពុធ ធារី ជាតំណាងអោយរុះរើសំណង់អាជីវកម្ម ចេញពីដីឡូត៍លេខ ៤៧០ ផ្លូវព្រះមុនីវង្ស សង្កាត់ទន្លេបាសាក់ ខណ្ឌ ចំការមន ក្រុង ភ្នំពេញ ចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

៥- បង្គាប់អោយឈ្មោះ ភ្លី ញ៉ឹង ភេទស្រី អាយុ ៥៨ ឆ្នាំ សងប្រាក់ថ្លៃឈ្នួលដី ចំនួន ២៥០០ដុល្លាអាមេរិក "ពីរពាន់ប្រាំរយដុល្លាអាមេរិក" អោយទៅឈ្មោះជា ស្រ៊ុយ ភេទប្រុស អាយុ ៤១ ឆ្នាំ គិតត្រឹមខែ០៣.១៩៩៩ ក្នុងតម្លៃឈ្នួល ២៥០ដុល្លាអាមេរិក "ពីររយហាសិបដុល្លាអាមេរិក" ក្នុងមួយខែ និង ត្រូវបានគិតថ្លៃឈ្នួលនេះបន្ត ចាប់ពីខែ ០៤ ឆ្នាំ ១៩៩៩ រហូតដល់

– – –

សំណង់អាជីវកម្មត្រូវបានរុះរើអស់ ចេញពីដីឡូត៍លេខ ៤៧០ ផ្លូវ ព្រះមុនីវង្ស សង្កាត់ ទន្លេបាសាក់ ខណ្ឌ ចំការមន ក្រុងភ្នំពេញ និង បង្គាប់អោយឈ្មោះ មាស សេង ភេទប្រុស អាយុ ៥២ ឆ្នាំដែលមានមេធាវីឈ្មោះ ពុធ ធារី ជាតំណាងសងថ្លៃប្រាក់ឈ្នួលដីចំនួន ៤៣០០ដុល្លារអាមេរិក " បួនពាន់បីរយដុល្លារអាមេរិក " អោយទៅឈ្មោះ ជា ស្រួយ ភេទប្រុស អាយុ ៤១ ឆ្នាំ គិតត្រឹមខែ០៣.១៩៩៩ ក្នុងតម្លៃឈ្នួល ៥០០ដុល្លារអាមេរិក " ប្រាំរយដុល្លារអាមេរិក " ក្នុងមួយខែ និង ត្រូវបានគិតថ្លៃឈ្នួលនេះបន្ត ចាប់ពីខែ ០៤ ឆ្នាំ ១៩៩៩ រហូតដល់សំណង់អាជីវកម្មត្រូវបានរុះរើអស់ចេញពីដីឡូត៍លេខ ៤៧០ ផ្លូវ ព្រះមុនីវង្ស សង្កាត់ ទន្លេបាសាក់ ខណ្ឌ ចំការមន ក្រុងភ្នំពេញ ។ ក្នុងករណីឈ្មោះ អ៊ូ ពឿង និង ឈ្មោះ មាស សេង រឹងរូសមិនព្រមសងប្រាក់គ្រប់ចំនួន អោយទៅដើមចោទ សំរេចដាក់គុកបង្ខំរូបកាយ លើឈ្មោះ អ៊ូ ពឿង និង ឈ្មោះ មាស សេង ចំនួន ៨ខែ " ប្រាំបីខែ " តាមមាត្រា១៣៣ នៃច្បាប់ស្តីពីវិធីអនុវត្តនីតិវិធីសាលក្រមរដ្ឋប្បវេណី ។

៦_ បង្គាប់អោយចុងចម្លើយឈ្មោះ អ៊ូ ពឿង និង ចុងចម្លើយឈ្មោះ មាស សេង ដែលមានមេធាវី និង ជាតំណាងឈ្មោះ ពុធ ធារី រួមគ្នាបង់ប្រាក់ប្រដាប់ក្តី ចំនួន ៧០០០រៀល គឺពន្ធចុះបញ្ជីក្តី និង ពន្ធធ្លឹង ១៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០រៀល រង្វាន់អ្នកប្រគល់ដីកាកោះ ៥០០០រៀល ប្រាក់នេះត្រូវបានយកពីដើមចោទ បានបង់រួចហើយ ។ កាលបើមួយបណ្តឹងឧទ្ធរណ៍ បង្គាប់អោយចុងចម្លើយឈ្មោះ អ៊ូ ពឿង និង ចុងចម្លើយឈ្មោះ មាស សេង ដែលមានមេធាវី និង ជាតំណាងឈ្មោះ ពុធ ធារី រួមគ្នាសងប្រាក់នេះទៅដើមចោទវិញ និង បង់ពន្ធសមាមាត្រ ចំនួន ១ភាគរយ លើតម្លៃប្រាក់ថ្លៃឈ្នួលទាំងអស់ ដែលសងទៅដើមចោទ ។

៧_ សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខគូក្តី សំរេចបើកផ្លូវឧទ្ធរណ៍ក្នុងកំណត់ច្បាប់ គិតពីប្រកាសសាលក្រមនេះតទៅ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៧៦ " ក " ចុះថ្ងៃទី ១៣.១០.៩៩ របស់ឈ្មោះ ជា ស្រួយ ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ៩៤ " ក " ចុះថ្ងៃទី ២២.០៩.១៩៩៩ របស់តុលាការក្រុងភ្នំពេញ លើសេចក្តីសំរេចទាំងមូល ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៨០ " ក " ចុះថ្ងៃទី១៨.១០.១៩៩៩ របស់ឈ្មោះ មាស សេង ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ៩៤ " ក " ចុះថ្ងៃទី ២២.៩.១៩៩៩ របស់តុលាការក្រុងភ្នំពេញ លើសេចក្តីសំរេចទាំងមូល ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៨១ " ក " ចុះថ្ងៃទី ១៩.១០.១៩៩៩ របស់ឈ្មោះ អ៊ូ ពឿង ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ៩៤ " ក " ចុះថ្ងៃទី ២២.៩.១៩៩៩ របស់តុលាការក្រុងភ្នំពេញ លើសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីការបៀបលេខ ០៦ ចុះថ្ងៃទី ១០.២.២០០០ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :_

១_ បំបែកសំណុំរឿងក្តីនេះជាពីរ :

_ សំណុំរឿងទីមួយ ដែលមានដើមចោទឈ្មោះ អ៊ុំ ជិនណាន តំណាងដោយឈ្មោះ ជា ស្រ៊ុយ និង ចុងចម្លើយឈ្មោះ មាស សេង ។

_ សំណុំរឿងទីពីរ ដែលមានដើមចោទឈ្មោះ អ៊ុំ ជិនណាន តំណាងដោយឈ្មោះ ជា ស្រ៊ុយ និង ចុងចម្លើយឈ្មោះ អ៊ុំ ពៀង ។

២_ សាលដីការបៀបនេះប្រកាសជាសាធារណៈ ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៦៤ " យ " ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :_

១_ ទទួលបណ្តឹងឧទ្ធរណ៍របស់ឈ្មោះ មាស សេង ចុះថ្ងៃទី ១៨.១០.១៩៩៩ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២_ ទទួលបណ្តឹងឧទ្ធរណ៍របស់ដើមចោទ ចុះថ្ងៃទី ១៣.១០.១៩៩៩ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

៣_ ទទួលស្គាល់លិខិតពឹងពាក់មេធាវីរបស់ចុងចម្លើយ និង លិខិតពឹងពាក់មេធាវីរបស់ដើមចោទ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

៤_ បដិសេធសាលក្រមរដ្ឋប្បវេណីលេខ ៩៤ " ក " ចុះថ្ងៃទី ២២.៩.១៩៩៩ របស់តុលាការក្រុងភ្នំពេញ ចោលជាអសារបង់ ។

៥_ រំលាយកិច្ចសន្យាជួលរវាងដើមចោទ និង ចុងចម្លើយចោលជាអសារបង់ ។

៦_ បង្គាប់អោយឈ្មោះមាស សេង ជាចុងចម្លើយសងប្រាក់ថ្លៃឈ្នួលដី ចំនួន ៥០០ដុល្លាអាមេរិក " ប្រាំរយ " ក្នុងមួយខែ គិតពីខែ សីហា ឆ្នាំ ១៩៩៨ រហូតដល់ថ្ងៃចាកចេញ និង រុះរើសំណង់សំភារៈចេញពីដីជាកម្មវត្ថុ នៃកិច្ចសន្យាជួលទៅអោយដើមចោទជាម្ចាស់ តាមវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ១៤.២៧៧ ចុះថ្ងៃទី ៣០.៣.១៩៩៣ របស់សាលាក្រុងភ្នំពេញ វិញ ។ សំណូមពរលើសពីនេះបដិសេធចោល ។

ករណីនឹងរូបមិនព្រមសងបង្គាប់អោយដាក់គុកបង្ខំរូបកាយដើម្បីទាមទារប្រាក់ឈ្នួល តាមបញ្ញត្តិមាត្រា ១៣៣ នៃច្បាប់ស្តីពីនីតិវិធីអនុវត្តសាលក្រមរដ្ឋប្បវេណី ។

៧_ កាត់យកប្រាក់ប្រដាប់ក្តីដាក់សាលាឧទ្ធរណ៍ ចំនួន ១៣.០០០រៀល គឺពន្ធចុះបញ្ជីក្តី ពន្ធរឹង ២៥៥០រៀល រង្វាន់ក្រឡាបញ្ជីការគិតប្រាក់ ៤៥០រៀល ចំណាយក្នុងកិច្ចប្រគល់ដីកាកោះ ៥០០០រៀល និង ចំណាយលើអាផ្ទានតុលាការ ៥០០០រៀល សរុប ១៣.០០០រៀល ។

_ បង្គាប់អោយឈ្មោះ មាស សេង ជាចុងចម្លើយ បង់ពន្ធសមាមាត្រ ១ភាគរយលើប្រាក់ថ្លៃឈ្នួលដី ។ ប្រាក់ពន្ធនេះត្រូវបានជាប្រយោជន៍ថវិកាជាតិ ៨០ភាគរយ និង បានជារង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ២០ភាគរយ ។

៨_ សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូក្តីបើកផ្លូវសារទុក្ខក្នុងកំណត់ច្បាប់ ។

--- ---

បានឃើញបណ្តឹងសាទុក្ខលេខ ៣៩៣ ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០០ របស់លោក មាស សេង ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៦៥ "យ" ចុះថ្ងៃទី ០៧ ខែសីហា ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍លើសេចក្តីសំរេចទាំងមូល ។

បានឃើញសារណារបស់លោក មាស សេង ចុះថ្ងៃទី ២៩.១២.២០០០ ។

បានឃើញសារណាតបរបស់លោក ជា យាម ចុះថ្ងៃទី ២២.០២.២០០១ ។

បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់មហាអយ្យការថា ៖

សាលដីការដ្ឋប្បវេណីលេខ ៦៥ "យ" ចុះថ្ងៃទី ០៧.៨.២០០០ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ហើយ ។

សូមក្រុមប្រឹក្សាជំនុំជំរះសំរេចតាមច្បាប់ ។

បានស្តាប់អំណានសារណារបស់លោក មាស សេង ជាចុងចម្លើយ និង ជាម្ចាស់បណ្តឹងសាទុក្ខ ។

បានស្តាប់អំណានសារណាតបរបស់លោក ជា យាម "តំណាងអោយលោកអ៊ុំ ជិនឈាន" ជាដើមចោទ និង ជាចុងបណ្តឹងសាទុក្ខ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក ម៉ែម វុន ជាមេធាវី បានលើកឡើងថា ៖ ដីឡូតិ៍ទីតាំងលេខ ៤៧០ ផ្លូវព្រះមុនីវង្ស ជាកម្មសិទ្ធិស្របច្បាប់របស់លោក អ៊ុំ ជិនឈាន និងភីងសុងយុន ក្រោយពីគាត់បានធ្វើបណ្ណ័សំគាល់សិទ្ធិកាន់កាប់ដីរួចហើយអ្នកទាំងពីរបានអោយឈ្មោះ ជា ស្រួយ នៅចាំថែរក្សាដីនោះ ។

នៅឆ្នាំ១៩៩៥ ជា ស្រួយ បានជួលដីខាងលើអោយទៅឈ្មោះ អ៊ុំ ញ៉ៀង ធ្វើសិប្បកម្ម តុ ទូ លើកលែងតែផ្ទះមួយមិនជួលអោយទេ គឺ ជា ស្រួយ ចាក់សោរទុក ។

តាមចម្លើយរបស់សាក្សីឈ្មោះ ចាន់ សេង បានបញ្ជាក់ថា ៖ នៅឆ្នាំ ១៩៩៦ ខ្លួនបាននាំឈ្មោះ មាស សេង ទៅជួបឈ្មោះ ជា ស្រួយ ដើម្បីនិយាយពីរឿងជួលដីធ្វើកន្លែងជួសជុលរថយន្ត ហើយឈ្មោះ ជា ស្រួយ និយាយថា មិនបាច់ធ្វើកិច្ចសន្យាទេ ។

នៅតុលាការក្រុងភ្នំពេញឈ្មោះអ៊ុំ ញ៉ៀង និង ឈ្មោះ មាស សេង បានឆ្លើយសារភាពថា ខ្លួន គិតជាបានធ្វើកិច្ចសន្យាជួលដីឡូតិ៍លេខ ៤៧០នេះពីឈ្មោះ ជា ស្រួយ និង នៅជំពាក់ប្រាក់ថ្លៃឈ្នួលពិតមែន ។

សំណូមពរសុំអោយតុលាការកំពូល តម្កល់សាលដីការបស់សាលាឧទ្ធរណ៍ទាំងមូល ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សារណារបស់គូភាគី និង សេចក្តីសន្និដ្ឋានការពាររបស់មេធាវីដើមចោទ .

--- ---

- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ .

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៣៩៣ ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០០ របស់លោក មាស សេង ធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូល អាចលើកឡើងនេះមកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការដែលលោក មាស សេង លើកឡើងក្នុងសារណា ចុះថ្ងៃទី២៩ ខែ ធ្នូ ឆ្នាំ ២០០០ របស់លោកថា ពុំមានកិច្ចសន្យាជួលជាលាយលក្ខណ៍អក្សរទេ ដែលតាមមាត្រា ៤, ១០១ និង ១០២ នៃក្រឹត្យ-ច្បាប់លេខ ៣៨ក្រច ចុះថ្ងៃទី២៨.១០.៨៨ បញ្ជាក់ថាលោកពុំបានជួលដីពីលោក ជា ស្រួយ ប្រាកដមែននោះជាការពុំត្រឹមត្រូវទេពីព្រោះលោកបានឆ្លើយទទួលស្គាល់នៅយុត្តិធម៌ខណ្ឌចំការមន និង នៅតុលាការក្រុងភ្នំពេញរួចហើយថា លោកពិតជាបានជួលដីនេះ និង បានបង់ថ្លៃឈ្នួលហើយខ្លះ នៅពុំទាន់បង់ខ្លះ និង សុំជួលបន្តទៀត ។

- យល់ឃើញថា ការដែលលោក មាស សេង លើកក្នុងសារណារបស់លោកថាលោករស់នៅ និង កាន់កាប់ដីទំនាស់នេះតាំងពីឆ្នាំ ១៩៨០រហូតដល់ឆ្នាំ ១៩៩៩ ដែលនាំអោយដើមចោទធ្លោះសិទ្ធិតាមក្រឹត្យ-ច្បាប់លេខ ៣៨ក្រច ចុះថ្ងៃទី២៨.១០.៨៨ និងតាមមាត្រា៦២, ៦៤ ,៦៥ និង ៧៤ នៃច្បាប់ភូមិបាលនោះគឺ ជាការភាន់ច្រឡំពីព្រោះការជួលនេះពុំទាន់ផុតប្រាំឆ្នាំទេ ហើយដីនេះមានបណ្ណ័សំគាល់សិទ្ធិកាន់កាប់រួចទៅហើយ ពុំមែនជាដីភោគៈទេ ដូច្នេះដីកម្មសិទ្ធិពុំត្រូវបានធ្លោះសិទ្ធិដោយសារអាជ្ញាយុកាលឡើយ ។

- យល់ឃើញថា ការដែលលោក មាស សេង ពុំទទួលស្គាល់លោក ជា ស្រួយ ជាតំណាងអោយដើមចោទនោះជាការពុំត្រឹមត្រូវទេពីព្រោះលោក បានទទួលស្គាល់ថា លោកបានជួលដីនេះពីលោក ជា ស្រួយ ហើយដើមចោទគឺ លោក អ៊ូ ជិនណាន និង លោក ភិង សុងឃុន បានផ្ទេរសិទ្ធិអោយលោក ជា ស្រួយ នៅមុខតុលាការរួចហើយ ម្យ៉ាងទៀតសាលាឧទ្ធរណ៍ពុំបានសំរេចប្រគល់ដី និង ប្រាក់ឈ្នួលអោយលោក ជា ស្រួយ ទេ គឺអោយទៅលោក អ៊ូ ជិនណាន និង លោក ភិង សុងឃុន ដែលជាកម្មសិទ្ធិករនៃដីទំនាស់នេះផ្ទាល់ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ៦៤ "យ" ចុះថ្ងៃទី ០៧.៨.២០០០ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ហើយ ។

## ហេតុដូច្នេះ

### វិនិច្ឆ័យសេចក្តីកំបាំងមុខគូក្តី ប៉ុន្តែចាត់ទុកជាចំពោះមុខ

១- ទទួលបណ្តឹងសាទុក្ខលេខ ៣៩៣ ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០០ របស់លោក មាស សេង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

--- ---

២_ តម្កល់សាលដីការដ្ឋប្បវេណីលេខ ៦៤ "យ" ចុះថ្ងៃទី០៧ ខែ សីហា ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣_ រឹបអូសប្រាក់ប្រដាប់ក្ដី ចំនួន ១៩.០០០រៀល ដែលលោក អ៊ុំ ជិនឈាន បានបង់ ជួសរួចហើយគឺ :_

_ ពន្ធចុះបញ្ជីក្ដី និង ពន្ធតាំង ចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ ចំនួន ៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

_ ចំណាយលើកិច្ចប្រគល់ដីកាកោះ ចំនួន ១៥.០០០រៀល សរុប១៩.០០០រៀល ហើយតម្រូវអោយលោក មាស សេង សងប្រាក់ ១៩.០០០រៀលនេះទៅលោកអ៊ុំ ជិនឈាន វិញ។

បង្គាប់អោយលោក មាស សេង បង់ពន្ធសមាមាត្រ ១ភាគរយលើប្រាក់ថ្លៃឈ្នួលដី ទាំងអស់ ។

៤_ សាលដីកានេះប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី១០ ខែ ឧសភា ឆ្នាំ ២០០១ ។